Institut Pasteur du Cambodge

រៀបរៀងដោយ វេជ្ជ. ហេង សៃឃើម / វេជ្ជ. ពឹង យ៉ឹកស៊ីង / ខែមេសា ឆ្នាំ២០១៥

# វ៉ាក់សាំងបង្ការជំងឺបង្កដោយមេរោគពឺម៉ូកូក

## (PNEUMOCOCCAL VACCINE)

## ១- ហេតុអ្វីអ្នកត្រូវទទួលវ៉ាក់សាំងប្រភេទនេះ?

មេរោគពឺម៉ូកូកជាប្រភេទបាក់តេរីម៉្យាងដែលអាចឆ្លងពីមនុស្សម្នាក់ទៅម្នាក់ តាមរយៈការប៉ះពាល់ រឺនៅស្និតស្នាលនឹងអ្នកមានផ្ទុកមេរោគនេះ។ បាក់តេរីនេះអាចបណ្តាលអោយមានជំងឺរលាកត្រចៀក និងជំងឺធ្ងន់ធ្ងរផ្សេងទៀតដូចជា៖

- រលាកសួត
- រលាកស្រោមខួរ
- មេរោគជ្រៀតចូលក្នុងឈាមជាដើម។

ជំងឺរលាកស្រោមខួរដែលបង្កដោយមេរោគនេះ (Pneumococcal meningitis) អាចបណ្តាលអោយថ្លង់ និងខូចខួរក្បាល ប្រមាណជា ១០ ភាគរយនៃករណីជំងឺ។ ការព្យាបាលដោយថ្នាំ Penicillin និងថ្នាំផ្សះផ្សេងៗទៀត លែងមានប្រសិទ្ធភាពខ្ពស់ដូចមុនទៀតហើយ ដោយសារតែមេរោគពឺម៉ូកូកខ្លះបានស៊ាំនឹងពពួកថ្នាំទាំងនោះហើយ។ ដូចនេះ ការចាក់វ៉ាក់សាំងបង្ការជំងឺនេះពិតជាមានសារៈសំខាន់ណាស់។

## ២- វ៉ាក់សាំងបង្ការជំងឺបង្កដោយមេរោគពឺម៉ូកូក

វ៉ាក់សាំង Synflorix អាចបង្ការការបង្ករោគដោយពឺម៉ូកូក ចំនួន ១០ ក្រុម (មេរោគដែលអាចបង្ករោគលើមនុស្សនេះមានច្រើនក្រុម)។
វ៉ាក់សាំង Synflorix ត្រូវផ្តល់ដល់កុមារ តាមការណែនាំដូចខាងក្រោម៖

**អាយុតិចជាង ៦ ខែ (ត្រូវផ្តល់ ៤ ដង)**

ដូសទី១: ពេលកុមារអាយុ ១ ខែកន្លះ ទៅ ៦ ខែ
ដូសទី២: ១ ទៅ ២ ខែ បន្ទាប់ពីដូសទី ១
ដូសទី៣: ១ ទៅ ២ ខែ បន្ទាប់ពីដូសទី ២
ដូសទី៤: យ៉ាងតិច ៦ ខែ ពីដូសទី ៣

**អាយុ ពី ៧ ខែ ទៅ ១១ ខែ (ត្រូវផ្តល់ ៣ ដង)**

ដូសទី១: កុមារនៅ ចន្លោះអាយុ ៧ ទៅ ១១ ខែ
ដូសទី២: ១ ទៅ ២ ខែ បន្ទាប់ពីដូសទី ១
ដូសទី៣: យ៉ាងតិច ២ ខែ ក្រោយដូសទី ៣

**អាយុ ពី ១២ ខែ ទៅ ២៣ ខែ (ត្រូវផ្តល់ ២ ដង)**

ដូសទី១: កុមារនៅចន្លោះអាយុ ១២ ទៅ ២៣ ខែ
ដូសទី២: ២ ខែ បន្ទាប់ពីដូសទី ១

## ៣- តើកុមារណាខ្លះ ដែលមិនគួរទទួលវ៉ាក់សាំងនេះ?

- កុមារដែលធ្លាប់មានប្រវត្តិប្រតិកម្មធ្ងន់ធ្ងរ ជាមួយវ៉ាក់សាំងប្រភេទនេះពីមុន ឬ ធ្លាប់ប្រតិកម្មធ្ងន់ធ្ងរជាមួយសមាសធាតុផ្សំផ្សេងទៀតមានក្នុងវ៉ាក់សាំងនេះ
- សម្រាប់កុមារដែលកំពុងមានជំងឺ ការផ្តល់វ៉ាក់សាំងគួរត្រូវពន្យាពេលរហូតដល់កុមារជាសះស្បើយសិន

## ៤- ផលវិបាកដែលអាចកើតមានក្រោយពេលចាក់វ៉ាក់សាំងនេះ

ក៏ដូចជាឱសថផ្សេងទៀតដែរ វ៉ាក់សាំងអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរដូចជា ប្រតិកម្ម អាលែកស៊ីជាដើម។ ប៉ុន្តែលទ្ធភាពដែលវ៉ាក់សាំងនេះអាចបណ្តាលអោយមានផលវិបាកធ្ងន់ធ្ងរមានតិចតួចបំផុត។ ផលវិបាកដែលអាចកើតឡើងរួមមាន៖

- ឈឺ ឬ ហើមត្រង់កន្លែងចាក់
- គ្រុនក្តៅ ឈឺក្បាល
- ឡើងកន្ទួលក្រហមលើស្បែក
- ក្អួងយំច្រើន រញ៉ាំរញ៉ូវ
- ប្រតិកម្មធ្ងន់ធ្ងរ (កម្រមានណាស់)

កុមារតូចៗដែលចាក់វ៉ាក់សាំងនេះ ក្នុងពេលតែមួយជាមួយវ៉ាក់សាំងផ្តាសាយ អាចមានអការៈក្តៅខ្លួនខ្លាំង។

**ប្រសិនបើមានសញ្ញាប្រតិកម្មធ្ងន់ធ្ងរ សូមជូនដំណឹងដល់គ្រូពេទ្យជាបន្ទាន់!**

Institut Pasteur du Cambodge